**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**អាជ្ញាធរអគ្គិសនីកម្ពុជា**

លេខ៤៨១ សាក.១៥ អអក

ភ្នំពេញ, ថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៥

# សេចក្តីជូនដំណឹងរបស់អាជ្ញាធរអគ្គិសនីកម្ពុជា ស្តីពីការបញ្ចុះអត្រាថ្លៃផ្គត់ផ្គង់អគ្គិសនីនៅលើកោះដាច់ សង្កាត់កោះដាច់ ខណ្ឌជ្រោយចង្វា រាជធានីភ្នំពេញ និងនៅលើកោះឧកញ៉ាតី ឃុំឧកញ៉ាតី ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល ក្នុងតំបន់ផ្គត់ផ្គង់អគ្គិសនីរបស់សេវាករឈ្មោះ លាង ឈុននី សេវាករឈ្មោះ ស៊ុយ ចំណាន

<u>យោង</u>៖ - ការតភ្ជាប់ប្រភពអគ្គិសនីពីអគ្គិសនីកម្ពុជា នៅចុងខែតុលា ឆ្នាំ២០១៥

- ការពិនិត្យគណនាថ្លៃដើម និងថ្លៃលក់ក្រោយការតភ្ជាប់ប្រភពថ្មីរបស់នាយកដ្ឋានបញ្ជីថ្លៃលក់នៃអាជ្ញាធរអគ្គិសនីកម្ពុជា ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៥

អាជ្ញាធរអគ្គិសនីកម្ពុជា សូមជម្រាបជូនសាធារណជន **អ្នកប្រើប្រាស់អគ្គិសនីក្នុងតំបន់ផ្គត់ផ្គង់អគ្គិសនី** របស់សេវាករឈ្មោះ លាង ឈុននី និងសេវាករឈ្មោះ ស៊ុយ ចំណាន នៅលើកោះដាច់ សង្កាត់កោះដាច់ ខណ្ឌជ្រោយចង្វា រាជធានីភ្នំពេញ និងនៅលើកោះឧកញ៉ាតី ឃុំកោះឧកញ៉ាតី ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល មេត្តាជ្រាបថា លើមូលដ្ឋាននៃយុទ្ធសាស្ត្ររុញប្រភពអគ្គិសនីដែលមានថ្លៃថោកចេញពីអនុស្ថានីយបណ្តាញជាតិ **អគ្គិសនីកម្ពុជា** បានធ្វើការវិនិយោគពង្រីកខ្សែបណ្តាញបញ្ជូនរងអគ្គិសនី ២២ kV កប់បាតទន្លេ បញ្ជូនប្រភពអគ្គិសនីទៅផ្គត់ផ្គង់ឲ្យតំបន់អាជ្ញាប័ណ្ណចែកចាយនៅលើកោះទាំង ២ ដែលកំពុងប្រើម៉ាស៊ីនម៉ាស៊ីនផលិតអគ្គិសនី ដើម្បីអាចបន្ថយអត្រាថ្លៃលក់បច្ចុប្បន្ន ឲ្យថយចុះជាបន្តបន្ទាប់ សម្រួលដល់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ។ ជាមួយគ្នានឹងការវិនិយោគរបស់អគ្គិសនីកម្ពុជា អាជ្ញាធរអគ្គិសនីកម្ពុជាក៏បានជម្រុញឱ្យសេវាករទាំង ២ ត្រៀមរៀបចំប្រព័ន្ធតភ្ជាប់ និងពង្រីកបណ្តាញចែកចាយទៅគ្រប់ភូមិទាំងអស់ដែលនៅសល់ក្នុងតំបន់អាជ្ញាប័ណ្ណរបស់ខ្លួន។ តាមការពិនិត្យ វិភាគថ្លៃដើមអគ្គិសនីនៅតំបន់របស់សេវាករទាំង ២ ឡើងវិញ ក្នុងសេណារីយ៉ូមានប្រភពអគ្គិសនីថោកតំបូង ស្របតាមការកំណត់របស់ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា ឃើញថា ថ្លៃដើមនៅមានកម្រិត ព្រោះទំហំទីផ្សារលក់ថាមពលរបស់សេវាករទាំង ២ នៅតូច ធៀបនឹងទុនវិនិយោគ និងត្រូវប្រើប្រាស់ទុនថែមទៀត ដើម្បីកែលម្អឲ្យបានត្រឹមត្រូវតាមស្តង់ដាបច្ចេកទេសកំណត់ និងពង្រីកបណ្តាញចែកចាយបន្ថែម។

យោងតាមការគណនាថ្លៃលក់តាមថ្លៃប្រភពថ្មីនេះ អាជ្ញាធរអគ្គិសនីកម្ពុជាសម្រេច និងអនុញ្ញាតឱ្យសេវាករឈ្មោះ លាង ឈុននី ធ្វើសេវាកម្មផ្គត់ផ្គង់អគ្គិសនីនៅលើកោះដាច់ សង្កាត់កោះដាច់ ខណ្ឌជ្រោយចង្វា



**អាជ្ញាធរអគ្គិសនីកម្ពុជា** : ផ្ទះលេខ ០២ ផ្លូវលេខ ២៨២ (ផ្លូវបត់ស្តាំទី ១ ខាងត្បូងវិមានឯករាជ្យ) សង្កាត់បឹងកេងកង ១ ខណ្ឌចំការមន រាជធានីភ្នំពេញ

ទូរស័ព្ទ : ០២៣ ២១៧ ៦៥៤ / ៩៨៧ ៨៩៨ ទូរសារ : ០២៣ ២១៤ ១៤៤, អ៊ីម៉ែល : admin@eac.gov.kh ; Website : www.eac.gov.kh

រាជធានីភ្នំពេញ និងសេវាករឈ្មោះ ស៊ុយ ចំណាន ធ្វើសេវាកម្មផ្គត់ផ្គង់អគ្គិសនីនៅលើកោះឧកញ៉ាតី ឃុំកោះឧកញ៉ាតី ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល បញ្ចុះអត្រាថ្លៃលក់បច្ចុប្បន្ន ពី ២,១០០ រៀល/គីឡូវ៉ាត់ម៉ោង និង ពី ២,៣០០ រៀល/គីឡូវ៉ាត់ម៉ោង មកអត្រាថ្លៃលក់ថ្មី ស្មើ ១,២០០ រៀល/គីឡូវ៉ាត់ម៉ោង គិតលើថាមពលប្រើប្រាស់ ចាប់ពីខែវិច្ឆិកា ឆ្នាំ២០១៥ រហូតខែមីនា ឆ្នាំ២០១៦ ។ អត្រាថ្លៃលក់ក្រោយខែមីនា ឆ្នាំ២០១៦ អាជ្ញាធរអគ្គិសនីកម្ពុជា នឹងកំណត់ឡើងវិញ តាមផែនការបន្ថយអត្រា និងគម្លាតថ្លៃលក់របស់រាជរដ្ឋាភិបាល។

អាស្រ័យហេតុនេះ សូមអ្នកប្រើប្រាស់អគ្គិសនី អាជ្ញាធរមូលដ្ឋាន និងអ្នកពាក់ព័ន្ធទាំងអស់ ក្នុងតំបន់ផ្គត់ផ្គង់អគ្គិសនីរបស់សេវាករឈ្មោះ លាង ឈុននី និងសេវាករឈ្មោះ ស៊ុយ ចំណាន និងសេវាករទាំង ២ មេត្តាជ្រាបជាព័ត៌មាន និងអនុវត្តឲ្យមានប្រសិទ្ធភាព។

**អាជ្ញាធរអគ្គិសនីកម្ពុជា**

**ប្រធាន**

**បណ្ឌិត.ធី នរិន្ទ**

<u>ចម្លងជូន</u> ៖

- ក្រសួងរ៉ែ និងថាមពល
- សាលារាជធានីភ្នំពេញ
- សាលាខេត្តកណ្តាល
- មន្ទីររ៉ែ និងថាមពល រាជធានីភ្នំពេញ
- មន្ទីររ៉ែ និងថាមពល ខេត្តកណ្តាល
- សាលាខណ្ឌជ្រោយចង្វា
- សាលាស្រុកខ្សាច់កណ្តាល
- សាលាសង្កាត់កោះដាច់
- សាលាឃុំកោះឧកញ៉ាតី

"ដើម្បីជូនជ្រាប"

- សេវាករ លាង ឈុននី
- សេវាករ ស៊ុយ ចំណាន

"ដើម្បីផ្សព្វផ្សាយ និងអនុវត្ត"

- ឯកសារ-កាលប្បវត្តិ



**អាជ្ញាធរអគ្គិសនីកម្ពុជា** : ផ្ទះលេខ ០២ ផ្លូវលេខ ២៨២ (ផ្លូវបត់ស្តាំទី ១ ខាងត្បូងវិមានឯករាជ្យ) សង្កាត់បឹងកេងកង ១ ខណ្ឌចំការមន រាជធានីភ្នំពេញ,
ទូរស័ព្ទ : ០២៣ ២១៧ ៦៥៤ / ៩៨៧ ៨៩៨ ទូរសារ : ០២៣ ២១៤ ១៤៤, អ៊ីម៉ែល : admin@eac.gov.kh ; Website : www.eac.gov.kh